Reçu le 15-2-5…

INDOCHINE FRANÇAISE
RÉGIE DU DÉPÔT LÉGAL

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

« Kampuchéak Souriya »

ពុទ្ធសាសនបណ្ឌិត្យ
INSTITUT BOUDDHIQUE

…ណ្ណាល័យជាតិ
សាលអាន
C.078.2
ពុទ្ធសាសនបណ្ឌិត្យ

Décembre 1951

ឆ្នាំទី ២៣ ខែធ្នូ លេខ ១២
ព. ស. ២៤៩៤ — គ. ស. ១៩៥១

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ


| ផ្នែកសាសនា | បញ្ជីរឿង | ទំព័រ |
|---|---|---|
| ពុទ្ធសាសនានិងគ្រិស្តសាសនា (សន្និសីទ លោកវេជ្ជបណ្ឌិតមីតូត) (ចប់)... | លោកភ័យ-ប៊ុក .......... | ៨៨៦ |
| ពន្ធិអាស៊ីទ្វីប (តមក)............ | លោកភ័យ-ប៊ុក .......... | ៨៩៥ |
| លោកបាលធម៌ ................ | ព្រះអរិយកស្សប គុង-ឈួន .. | ៩០២ |
| ករិធម្មភាសិត................ | ព្រះមហា ឡម-តាគ្រី ...... | ៩០៧ |

**ផ្នែកអក្សរសាស្ត្រ**

| | | |
|---|---|---|
| សុភាសិតប្រឌិតរឿង ............... | ព្រះមហា អ៊ុម-សុខ ...... | ៩១១ |
| រឿងអាយោនទាហានចាស់ .......... | សាស្ត្រាចារ្យផេង-ជ្រឹវ ..... | ៩១៤ |
| ការបណ្ដុះនិស្ស័យ (តមក)........ | ព្រះមហាឧត្តមវិជ្ជា ប៊ុង-ប៉ម ... | ៩២៥ |
| រឿងសាមកុក (តមក)........... | ឧកញ៉ា នូ-កន .......... | ៩៣០ |
| ព្រះរាជពង្សាវតារប្រទេសកម្ពុជា (តមក).. | ឧកញ៉ា ឈឹម-ក្រសេម..... | ៩៣៨ |
| រឿងអារក្សថ្លែងរឿងម្ភៃប្រាំ (តមក).... | លោកសាង-សាភ៊ិត....... | ៩៤២ |

**កំណត់ទីនីប្រវត្តិការណ៍**

| | | |
|---|---|---|
| ពិធីប្រឡងធម្មវិន័យ វត្តព្រះព្រហ្មរតន៍ ខែត្រសៀមរាប ................ | ព្រះមហា កែ-អឿន ...... | ៩៥៣ |



មួយឆ្នាំមាន ១២ សៀវភៅ — ដំឡៃឆ្នាំ ១៤៥ រ.០០

លោកបាលធម៌

# ព្រះបាឡាត់អរិយកស្សប គុង-ឈួន

វត្តបទុមវត្តី ក្រុងភ្នំពេញ

ទេសនាផ្សាយវិទ្យុឃោសនសព្ទ នៃប្រទេសកម្ពុជា កាលពីថ្ងៃ ៨ កោច ខែមិគសិរ
ឆ្នាំកុរនព្វស័ក ព. ស. ២៤៩០ (៤—១—៤៨)

---

នមត្ថុ រតនត្តយស្ស ។

ហិរោត្តប្បិយញ្ញេវ លោកំ បាលេតិ សាធុកំ ។

វេលានេះ អាត្មាភាព ត្រូវវេនសំដែងវិទ្យុធម្មទេសនា ថ្វាយជូន អស់លោកសប្បុរសទាំងឡាយស្ដាប់ ។

អាត្មាភាព នឹងសំដែង អំពីលោកបាលធម៌ គឺធម៌ជាគ្រឿងឃុំគ្រងរក្សាលោកឲ្យបានល្អ ។ ចុះធម៌អ្វីខ្លះ ដែលឈ្មោះថាលោកបាលធម៌? ហិរិ និងឱត្តប្បៈ ឈ្មោះថាលោកបាលធម៌ ។ ហិរិគឺអ្វី? គឺសេចក្ដីខ្មាសអំពើអាក្រក់គ្រប់យ៉ាង ។ ចុះឱត្តប្បៈ បានដល់អ្វី? បានដល់សេចក្ដីខ្លាចអំពើលាមកគ្រប់បែប ។ ចុះបើគ្រាន់តែខ្មាសនិងខ្លាចប៉ុណ្ណោះទេ ហេតុអ្វីក៏ឈ្មោះថាឃុំគ្រងរក្សាលោក? ហេតុថា លោកគឺពួកសត្វ ទោះជាគ្រហស្ថក្ដី បព្វជិតក្ដី បើបានបណ្ដុះហិរោត្តប្បធម៌នេះ មកដាក់ទុកក្នុងសន្ដាន ហើយប្រតិបត្តិតាមថែមទៀត, គ្រហស្ថ បព្វជិតនោះ អាចស្ទួយសព្វាង្គកាយទាំងមូល ឲ្យអណ្ដែតឡើងផុតអំពីគំនរនៃសេចក្ដីអាក្រក់គ្រប់

យ៉ាង ទីងកំពឹងកមមិនឲ្យសេចក្ដីលាមកកើតឡើងបានទៀត បានជាឈ្មោះថា គ្រប់គ្រងរក្សាលោក ។ តែលោកក្នុងទីនេះ សំដៅយកតែសត្វលោក គឺពួកមនុស្សមួយយ៉ាង ពុំបានពោលដល់សង្ខារលោកនិងឱកាសលោក ឡើយ ។

ឯហិរិឱត្តប្បៈ គឺខ្មាសនិងខ្លាចចំពោះអំពើទុច្ចរិត សេចក្ដីប្រព្រឹត្ត អាក្រក់ផ្លូវកាយ វាចា ចិត្តនេះ បើយើងគ្រាន់តែពោលថាខ្មាសៗ ខ្លាចៗ ត្រឹមតែបបូរមាត់ប៉ុណ្ណោះទេ នោះគឺឥតអំពើដែរ ។ សូមលើក គួរយ៉ាងដូចពួកពុទ្ធមាមកជនទាំងគ្រហស្ថបព្វជិត មានមុខងារជាអ្នកកាន់ ក្រិត្យប្រព្រឹត្តវិន័យ តាមផ្លូវពុទ្ធសាសនា, រដ្ឋាភិបាលជន មានមុខងារ ជាអ្នកប្រព្រឹត្តខ្លួនឲ្យតាំងនៅក្រោមរដ្ឋបញ្ញត្តិ គឺច្បាប់ដែលគេតែងតាំង ឡើងសម្រាប់ដែន ។

បព្វជិត បើពុំហ៊ានប្រព្រឹត្តកន្លងវិន័យពុទ្ធបញ្ញត្តិ ព្រោះខ្មាសគេ ព្រោះខ្លាចឧបជ្ឈាយាចារ្យផ្ដន្ទាទោស និងប្រជានិករគេហានិន្ទាប៉ុណ្ណោះ ទេ លុះដល់វេលាស្ងាត់កំបាំងក៏តាំងប្រព្រឹត្តល្មើសកន្លងវិន័យបញ្ញត្តិ សិក្ខាបទធំ-តូចតាមតែអំពើចិត្តទៅ ។

គ្រហស្ថជាពុទ្ធសាសនិកជន បើខ្មាស ខ្លាចដូចជាស្ត្រីក្រមុំមានរូប ល្អ ពុំហ៊ានចេញឆ្ងាយពីបន្ទប់ ដោយខ្លាចគេឯងមើលឃើញ ពុំនោះ សោតដូចកូនប្រុស-ស្រីប្អូនសិស្សដែលខ្មាសខ្លាចមាតាបិតាគ្រូបាអាចារ្យ

ផ្តន្ទាទោស ហើយពុំហ៊ានប្រព្រឹត្តអំពើអាក្រក់ លុះកំបាំងចេះតែធ្វើតាមចិត្តទៅ ។

ចំណែករដ្ឋាភិបាលផង បើខ្មាសខ្លាចពុំហ៊ានប្រព្រឹត្តល្មើសគន្លងរដ្ឋបញ្ញត្តិដោយគំនិតគោរព ព្រោះខ្លាចមហិស្សរាធិបតិផង លុះស្ងាត់កំបាំងកំតាំងរឹបជាន់សក្តិសក្តិនទៅតាំងអំណាច ។

ការខ្មាស ការខ្លាចបែបនេះ ពុំប្រសើរឡើយ ព្រោះជាអំពើដែលនាំឲ្យក្តៅក្រហាយខាងក្រោយ ។

លុះតែខ្មាស ខ្លាចផុះឡើងអំពីផ្លូវចិត្តរបស់ខ្លួន ចំពោះទោសកំហុសដែលកើតឡើងអំពីការល្មើសវិន័យបញ្ញត្តិ បុរេបញ្ញត្តិ ទាំងផ្លូវលោកផ្លូវធម៌ ដោយនឹកដល់ជាតិកំណើត វ័យ: សេចក្តីចំរើន, សេចក្តីក្លៀវក្លាអង់អាចនិងសេចក្តីចេះដឹងរបស់ខ្លួន ព្រមទាំងខ្លាចផលការតិះដៀលខ្លួនដោយខ្លួនឯង ខ្លាចអ្នកដទៃគេបាននិន្ទា ខ្លាចព្រះរាជអាជ្ញា ខ្លាចគតិដ៏អាក្រក់ហើយពុំធ្វើអំពើទុច្ចរិត ទើបរាប់ថាខ្មាស - ខ្លាច អាចជួយគ្រប់គ្រងអភិបាលគាំទ្រខ្លួនឲ្យបានសេចក្តីសុខ - ចំរើន និងសេចក្តីល្អទាំងក្នុងបច្ចុប្បន្ននេះនិងអនាគត ព្រមទាំងឲ្យរួចផុតអំពីសេចក្តីអាក្រក់ទៅបាន ។ សមតាមលំអានពុទ្ធភាសិតថា ធម្មោ ហវេ រក្ខតិ ធម្មចារឹ “ធម៌ (គឺហិរិឱត្តប្បៈ) រមែងរក្សាអ្នកប្រព្រឹត្តធម៌” ន ទុគ្គតឹ គច្ឆតិ ធម្មចារី “បុគ្គលអ្នកប្រព្រឹត្តធម៌ រមែងមិនទៅកាន់ទុគ្គតិ” ។ ព្រោះហេតុនេះ ហិរិនិងឱត្តប្បៈ ទើបបានឈ្មោះថាលោកបាលធម៌ ។

ហិរិឱត្តប្បធម៌នេះ បើអស់លោក-អ្នក ទាំងគ្រហស្ថ-បព្វជិត បានបង្កើនមកទុកក្នុងចិត្ត ឬបានប្រព្រឹត្តឲ្យល្អហើយ អាចបត់បង្វិលទឹកចិត្តគំនិតខឹងក្អករបស់លោកអ្នកទាំងឡាយ ឲ្យញញឹមញញែមរីករាយ ឈមមុខទៅរកគ្នាបានរាល់ទិវារាត្រី ។

កាលបើអស់លោក-អ្នក ដែលជាអ្នកស្រឡាញ់ ជាតិ សាសនា មហាក្សត្រិយ៍បានជ្រាបថាធម៌នេះ ពិតជាធម៌រក្សាលោកឲ្យបានល្អហើយ ក៏សូមខ្ជាក់ចោលនូវកំហាក ពោលគឺសេចក្តីអាក្រក់ ផ្លូវកាយវាចាចិត្ត ចេញចាកខ្លួនសន្តានឲ្យឆាប់ៗទៅ ហើយសូមខំប្រឹងកសាងបណ្តុះឬបំពេញ ហិរោត្តប្បធម៌ ដែលជាសញ្ញាករណៈរបស់យើងទាំងអស់គ្នា ឲ្យគ្រប់គ្រាន់ឡើង ដើម្បីនឹងបានជាឧត្តមគតិមួយ ដល់យុវនារី យុវជនដែលជាអ្នកដើរតាមក្រោយ យកជាគម្រាប់ផង ។

ទីបំផុតនេះ អាត្មាភាពសូមជូនពាក្យពរបទ ផ្ញើទុកចំពោះអស់លោកជារដ្ឋាភិបាល និងប្រជានិករ ព្រមទាំងយុវនារី យុវជនរួមជាតិថា: សូមកុំភ្លេចសច្ចៈ (សេចក្តីពិតត្រង់) ហើយកុំលះបង់ វិរិយៈ (សេចក្តីព្យាយាម) ក្នុងកាលដែលលោកអ្នកបានបំពេញនូវហិរោត្តប្បធម៌គ្រប់គ្រាន់ហើយនោះ ព្រោះសច្ចវិរិយធម៌នេះហើយ ដែលអាចសួយជួយជាតិ សាសនា មហាក្សត្រិយ៍ ព្រមទាំងមាតុភូមិរបស់យើង ឲ្យដំណើរជឿនលឿនទៅកាន់អារ្យធម៌ខាងអនាគត ។

ហេតុនេះ សូមអស់លោកជាមិត្តភាព ភាតរភាពទាំងឡាយ ទោះជាគ្រហស្ថក្តី បព្វជិតក្តី ដែលមានសមត្ថភាពយ៉ាងគ្រប់គ្រាន់ សូមកាន់នូវសទ្ធៈ សេចក្តីពិតត្រង់ ចំពោះមុខការរបស់ខ្លួន, សូមមានវីរិយៈ សេចក្តីប្រឹងប្រែងខ្នះខ្នែង ចំពោះមុខការរបស់ខ្លួន ឲ្យមុឺងម៉ាត់ឡើង, ព្រោះឱកាសនេះហើយដែលជាឱកាសមួយ គួរអស់លោក-អ្នកខំបំពេញសច្ចវិរិយៈ ទើបនឹងអាចបំបាត់នូវអំពើអយុត្តិធម៌ អំពើលញ្ចការរបស់ទុជ្ជន, មោហជនបានដោយងាយ ។

អាត្មាភាពសូមថ្វាយព្រះពរ ព្រាកដសិរីសួស្តីជ័យមង្គលព្រះជន្មសុខគ្រប់ប្រការ សូមកើតមានដល់ព្រះបាទសម្តេចព្រះបរមបពិត្រព្រះរាជ-សម្ភារដ៏ទ្រទ្រង់នូវព្រះគុណធម៌មហាប្រសើរកល់ទិវារាត្រី ព្រមទាំងប្រជានិករកម្ពុជរដ្ឋគ្រប់ភូមិ-ជាន់ សូមឲ្យបានប្រកបសុវត្ថិមង្គលសួស្តីតរៀងទៅ ! ។

សំដែងមកក្នុងលោកបាលធម៌ សូមសន្មតជាចប់ដោយសង្ខេបបុណ្ណោះ ឯវំ ។

ចប់

កវីជម្នះកាសំគ

# មហាឱម-ឆ៉ាគ្រី

ឃុំស្វាយប៉ោ ស្រុកសង្កែ ខេត្តបាត់ដំបង រៀបរៀង

ឃុន-សុវត្ថិផទី ឃួរ-អ៊ុន ពិនិត្យកែ

---

## ទោសនៃស្រុក

អ្នកប្រមឹក ផឹកស្រា ខឹងមេវ៉ាយ
តែងហិនហោច ខូចហិនហៃ ទ្រព្យសម្បត្តិ
រលត់ប៉ុន រលើងខ្ចាយ រលាយខ្ចាត់
វិនាសបង់ វិនាសបាត់ អស់សេសសល់ ។
អ្នកប្រមឹក តែងប្រមូល ចូលចិត្តឈ្លោះ
ពោលតំពេះ ពាក្យតំរក់ លាមកខ្វល់
ជេរបញ្ឆោះ ឈ្លោះបញ្ចោរ កោលាហល
កើតក្តីក្តាំ នាំប្តឹងផ្តល់ ដល់រដ្ឋបាល(១) ។
អ្នកប្រមឹក ផឹកស្រា ក្លាផាប់ដោក
បណ្តាលកេត បណ្តុះរូប ឲ្យពិការ(១)
ឲ្យក្តៅហួស ឲ្យជ្រួសហល់ រូបសង្ខារ
ឲ្យងងឹត ខូចវិចារ-ណញ្ញាណ ។

---

១ ត្ន ល, រ ជាឮស្រួយ, អាចយកប្រែកបន្ទឹងឆ្លោះបាន ។

អ្នកប្រមឹក តែងស្អុយខ្លួន ហោចគេក្ដីឈ្មោះ
ក្លាយសុះ ថាជាមនុស្ស ទ្រុស្ដីឈ្មោះពាន
ដើរត្រេសត្រាស ពាសទិសទី ដូចតិរច្ឆាន
អ្នកអាងប្រាណ បែកគ្រោកប្រាជ្ញ ឥតខ្លាចអ្វី ៗ
ឥតអៀនខ្មាស ឥតបិទបាំង បទគួរបិទ
ជាមនុស្សផិត ជាមនុស្សផុត ដោតកសី
ធ្វើបញ្ញា ឲ្យអន់ចុះ ឲ្យគុះទ្វី
ធ្វើស្មារតី ឲ្យវង្វេង ភ័ន្តវង្វេង ៗ
ការប្រមឹក ជាប្រមុខ ឆ្កួតល័លា
ធ្វើបុកពា ឲ្យថោកទាប ភាពអ្នកលេង
ដើរដជ្រែក មមកជ្រុល វ៉ៃបុកវ៉ៃជ្រង
តែម្នាក់ឯង ដើរផ្លូវមួយ ពោលទ្រគោះ ៗ

ពោលអំនួត អួតអំណាច រៀនកាចគោន
ប៉ុកក្រគោង គោងក្រអឺត ប្រឡោះបោះ
ដើរធ្លាក់ថ្លុក ជង្ហុកបឹង ត្រពាំងជ្រោះ
ពោលឡេះឡោះ ស្រែកឡូឡា ព្រឡូងឡាន ៗ
វ៉ៃបញ្ឈោះ ឈ្លោះបញ្ចោរ កូនប្រពន្ធ
ដេរបណ្ដូន ពោលបណ្ដាប់ ស័ព្ទគ្រេងគ្រាង

ក៏យបានឆ្នាំង ប៉ុនប៉ាំងបែក ក្រឡុបថ្ពាន
មាត់រ៉ូងក៏ង ពុំរ៉ូសក៏ស ពាសពេញស្រុក ។
គុតបង្អោរ ផុំបង្អាប គុំនអសោច
ដូចជាខ្មោច ហូរគម្រង់ សែនអផ្សុក
ផ្លូនដេកផ្លូល ដោយផងព្រៃ សុកម៉មុក
ផ្លូនតក្រុក ដើរទទ្រើក ញាប់ញ័រកាយ ។
ក៏សៃផើង ទៀនផំនោរ ដោរចំណាប់
អ្នកតាក់កាប់ ការតែស្លាប់ ឥតសោកស្តាយ
ឈប់ស្គាល់កូន ចៅប្រពន្ធ ឪពុកម្តាយ
ហ៊ានមើលងាយ ក៏យដេរលោក អ្នកមានគុណ ។

ប្រទំឡុំ ថាជាពួក ម៉ាកកឿនផឹក
ឃើញមុខម៉ែ ថែជាទឹក ថាប្រពន្ធ
ត្រង់មិនគួរ ថាជាគួរ បាបជាបុណ្យ
ទោសជាគុណ បុណ្យជាបាប សាបជាប្រៃ ។
ការប្រមឹក នាំប្រមាទ ខាតកុសល
នាំអំពល់ ផលអំពើ ប្រសើរក្រៃ
នាំបានទុក្ខ បុកម្នេញ ពេញផ្លូនវៃ
នាំចង្រៃ នាំបង្រាស ប្រាសព្រាត់គ្នា ។

នាំហោកពាប ត្រកូលញាតិ ជាតិផៅពង្ស
នាំឲ្យល្ងើ ភ្លើឲ្យល្ងង់ ឆ្កួតពាលា
នាំគេខ្ពើម ល្អើមល្អប់ គេខ្នា
នាំវេក បង់ទៀវគ្នា ជាអន្ទើន ៗ

នាំហាក់ហាប់ នាំជាប់គុក នរកគោក
នាំឲ្យសោក វិយោគសៅ យំស្រែង
នាំអន់អប្ប យ៉ាប់គេគ្រើឈ្មោះ យូរអន្ទើន
នាំឲ្យក្រន់ វែងគោតក្រែង វែងគោរព ៗ

ការប្រមឹក ជ: ប្រមុខ ទុក្ខបច្ចុប្បន្ន
ឃើញស្រូវកន់ តាន់ហាន់ណាស់ គួរតែឈប់
ឯបរលោក ធ្លាក់ទៅកាន់ ទុគ្គតិកត
គួរកុំងប់ ជាប់សុរា ណាខ្មែរអើយ !!! ៗ

លួចគេធ្លាប់ដៃ ដេកថ្ងៃធ្លាប់ភ្នែក
ផឹកស្រាធ្លាប់ស្រេក ជជែកធ្លាប់មាត់

ឧម - ខ៉ាគ្រី

សុភាសិតប្រចំតរឿង

ព្រះមហា អ៊ុម – សុខ

*សិស្សសាលាបាលីជាន់ខ្ពស់ ថ្នាក់ឆ្នាំទី ៤ "ខ"*

*រៀបរៀង*

---

គេជឿ សឹមប្រាប់

គេស្តាប់ សឹមបរហា

គេសួរចំអាត្មា សឹមឆ្លើយ ៗ

*សូមសាធុជនត្រងត្រាប់ស្តាប់និទាន "បក្សីនិងពានរ" ដូចតទៅនេះ:–*

នេះនឹងថាថ្លែង    បរហាសំដែងកាលគ្រា
ព្រហ្មទត្តរាជា    ត្រង់បុរីរម្យពារាណសី ៗ
កាលនោះមែនមាន    សកុណាមួយប្រាណប្រិមប្រិយ
ជាតិជាបក្សី    ត្រលេងត្រលោងសោភណា ៗ
ធ្វើសំបុកនៅ    នាផងព្រៃជ្រៅហិមវា
សែនសុខសថា –    ពរពិតគត់គមោះមួនមាំ ៗ
រដូវវស្សា    ភ្លៀងធ្លាក់ពសុធាជោគជាំ
រងាខ្ញុំ    នាំឲ្យសព្វសត្វព្រួយប្រាណ ៗ
កាលនោះមានស្វា    រងាឯកាឥតស្ថាន

បរបូលគ្រោះថ្កាន ប្រញប់ប្រាណរកទីអាស្រ័យ ។
បក្សីឃើញស្វា លំបាកអាត្មាពោះនៃ
ទើបពោលតាប់វៃ ថាហៃអើយបងពានរ ។
ដៃជើងបងឯង ប្រាកដជាក់ស្ដែងស្វាពរ
ដូចមនុស្សនិករ ម្ដេចមិនធ្វើផ្ទះគ្រាន់ជ្រក? ។
ស្វាឆ្លើយតបថា ហៃចៅបក្សាពនូក
ខ្ញុំនឹងស្វែងរក ធ្វើផ្ទះគ្រាន់ជ្រកម្ដេចបាន ។
ដៃជើងក្បាលខ្ញុំ ដូចមនុស្សតូចធំគ្រប់ប្រាណ
ប្រាជ្ញាខ្ញុំគ្មាន ធ្វើម្ដេចសាងស្ថានបាននៅ ។
គ្រលេងគ្រលោង ជាសត្វយិតយោងមនុស្សឡោ
ពោលថាលំនៅ មិនមានដល់មនុស្សបែបឯង ។
ទើបពោលទៀតថា ក្ដីសុខាមិនស្ដែង
ដល់មនុស្សបែបឯង ជាសត្វមានចិត្តសាហ៊ ។
រុិលរប៉ូច រហ័សផ្លេកដូចផ្លេះណា
ទ្រុស្ដមិត្តអាត្មា ដូចយ៉ាងបងស្វាឯងហ្នឹង ។
នៃពានរអើយ គួរកុំកន្ដើយទ្រមឹង
ចូរចាំប្រែងប្រឹង ស្វាផ៉ស្ទឹងខឹងគេឡើងទៅ ។
កុំខ្ជិលប្រអូស លះចិត្តស្រមូសហ្មងសៅ

កុំឲ្យមានទៅ ចូរទៅផ្ញើខ្លួនគ្រាន់ជ្រក ៗ
ពានរគិតថា អាផែនីបក្សាព់មក
ពោលពាក្យបំអក ថាអញជាសត្វទ្រុស្តមិត្ត ៗ
ចេះមានតែអញ សំផែនផ្លាលផ្លាញ់ឲ្យពិត
រឿនក៏ទ្រុស្តមិត្ត ឲ្យឃើញប្រច័ក្សផល់ព ៗ
គិតហើយស្ទុះផ្លោត ផ្លោះផ្លាញលោលោតម្នីម្នា
ចាប់ចុងព្រឹក្សា ហោចកេចសម្បុកបក្សី ៗ
ខូចខាតបែកបាក់ ផុះធ្លាយខ្ចាយធ្លាក់ជាសជី
សត្វស្វាបលែងស្តី ហើរបុតទីនោះហោង ៗ
លោកអ្នកចូរស្តាប់ កាន់តាមសណ្ដាប់កុំហ្មង
កុំមោះកន្ទង ពាក្យពិតភាសិតនេះណា ៗ
ចូរចាំឲ្យជាក់ បក្សីធ្លាយធ្លាក់គ្រឹះហា
ព្រោះតែអាត្មា ខ្វះនាទសត្វស្វាល្ងង់ទៅ ៗ
ពាលស្អប់ខុតខ បណ្ឌិតវៃឆ្លាតប្រពៅ,
ឈើគោលម្អមៅ តែងស្អប់បន្ទាត់ពេកក្រៃ ៗ
រុយស្អប់បុប្ផា, កម្រះបក្សាថ្លាថ្លៃ
ស្អប់លាមកក្រៃ ; គួរស្តាប់ឧបមេយ្យនេះហោង ៗ

អ៊ុម — ស៊ុខ